សកម្មភាព 2.5

## ការចងក្រងអ្នកធ្វើការតាមផ្ទះវ័យក្មេង

សេណារីយ៉ូសម្រាប់សម្តែង

តួនាទី៖

**សមាជិកសមាគមអ្នកធ្វើការតាមផ្ទះថ្នាក់ជាតិនៃប្រទេស Joyland (NDWAJ)៖**

- ប៉េមបា អាយុ២២ឆ្នាំ ជាសមាជិកស្ថាបនិកនិងជាថ្នាក់ដឹកនាំរបស់សមាគម NDWAJ ហើយជាអ្នកធ្វើការតាមផ្ទះ តាំងពីនាងអាយុ១៤ឆ្នាំ
- រីតា អាយុ១៧ឆ្នាំ, ជនចំណាកស្រុក, ជាសមាជិកសមាគមបានរយៈពេល១០ខែ ហើយជាអ្នកធ្វើការតាមផ្ទះ តាំងពីអាយុ១៣ឆ្នាំ

**អ្នកធ្វើការតាមផ្ទះវ័យក្មេង៖**

- ម៉ាលី អាយុ២២ឆ្នាំ ហើយជាអ្នកធ្វើការតាមផ្ទះ តាំងពីអាយុ១៥ឆ្នាំ
- ការីម៉ា អាយុ១៦ឆ្នាំ ហើយជាអ្នកធ្វើការតាមផ្ទះ តាំងពីអាយុ១៣ឆ្នាំ
- សុកណ្ណ (ប្រុស) អាយុ១៥ឆ្នាំ, ជនចំណាកស្រុក ហើយជាអ្នកធ្វើការតាមផ្ទះ តាំងពីអាយុ១២ឆ្នាំ

**ឈុត៖**

សមាជិកសមាគម NDWAJ បានទៅជួបអ្នកធ្វើការតាមផ្ទះវ័យក្មេងមួយក្រុម នៅក្នុងសួនមួយ ឬនៅក្នុងព្រះវិហារមួយ។ ប៉េមបា ដែលជាសមាជិករបស់សមាគម NDWAJ ចាប់តាំងពីបង្កើតឡើងតាំងពី៣ឆ្នាំមុនមកនោះស្គាល់ ការីម៉ា ដែលមកពីភូមិជាមួយគ្នា។ ប៉េមបា ជជែកជាមួយការីម៉ានិងមិត្តភក្តិរបស់នាង អំពីសមាគម NDWAJ ដោយបានអញ្ជើញពួកគេឲ្យចូលរួម។ រីតា និង អាម៉េដ ផ្តល់មូលហេតុដែលនាំឲ្យពួកគេបានចូលរួមជាមួយអង្គការ និងសភាពជាសមាជិក។ បុគ្គលដែលអាចក្លាយជាសមាជិកបាននោះ ម្នាក់ៗបានផ្តល់យ៉ាងហោចណាស់ ហេតុផលចំនួនមួយ អំពីមូលហេតុដែលខ្លួនមិនអាចឬមិនចង់ចូលរួមក្នុងសមាគម។ សមាជិកទាំងបីនាក់ ព្យាយាមបញ្ចុះបញ្ចូលពួកគេអំពីផលប្រយោជន៍ដែលទទួលបានពីការចូលរួមក្នុងសមាគម និងបានជំទាស់ទាំងនឹងមូលហេតុដែលពួកគេបានផ្តល់ឲ្យ។

**ព័ត៌មានសាវតា៖**

- សមាគម NDWAJ បង្កើតឡើងកាលពី៣ឆ្នាំមុន
- សមាគមនេះ មានសមាជិកចំនួន ៣០០នាក់៖ ជនជាតិក្នុងប្រទេស (២៥០នាក់) និងជនចំណាកស្រុ (៥០នាក់)
- ដូចអង្គការអ្នកធ្វើការតាមផ្ទះជាច្រើនទៀតដែរ សមាគមនេះមិនទាន់ចុះបញ្ជីទេ (ថ្នាក់ដឹកនាំ កំពុងពិភាក្សាអំពីបញ្ហានេះ)




- លក្ខន្តិកៈរបស់សមាគម មិនបានចែងអំពីអាយុអប្បបរមាក្នុងការក្លាយជាសមាជិកនោះទេ ទោះបីជាសមាជិកភាគមានអាយុ១៨ឆ្នាំ ឬលើសនេះក៏ដោយ
- អាយុអប្បបរមារបស់ប្រទេស Joyland កំណត់អាយុ ១៨ឆ្នាំ, ប៉ុន្តែ កុមារអាចធ្វើការបានចាប់ពីអាយុ ១៤ឆ្នាំ (បានតែការងារ "ស្រាលៗ" ប៉ុណ្ណោះ)។
- យោងតាមការសិក្សាថ្មីៗនេះ ១/៣នៃអ្នកធ្វើការតាមផ្ទះប្រហែលជា១លាននាក់ក្នុងប្រទេស Joyland តាមការប៉ាន់ប្រមាណ ស្ថិតនៅក្នុងចន្លោះអាយុ ១៤ ដល់ ១៧ឆ្នាំ

កុមារធ្វើការងារតាមផ្ទះ សម្តែងអំពីការជួញដូរ នៅតាមផ្លូវក្នុងប្រទេសឥណ្ឌា។
រូបថតដោយ៖ សហជីព Jharkhand Gharelu Kamgar